*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# តំណាង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុង
# ពិធីបើកកិច្ចប្រជុំរួមលើកទី ៣៥ នៃគណៈកម្មការតំបន់អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក និង គណៈកម្មការតំបន់អាស៊ីខាងត្បូងនៃអង្គការទេសចរណ៍ពិភពលោក (35th UNWTO CAP & CSA) អមដោយសន្និសីទអង្គការទេសចរណ៍ពិភពលោក ស្តីពីក្រមអន្តរជាតិសម្រាប់ការការពារទេសចរ

សណ្ឋាគារសុខា ភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២៣ វេលាម៉ោង ១០ ព្រឹក

- ឯកឧត្តម **ហ្សូរាប ប៉ូលូលីកាសវីលី** (Zurab Pololikashvili) អគ្គលេខាធិការ អង្គការទេសចរណ៍ពិភពលោក;
- ឯកឧត្តម **ដាតូស្រ៊ី ទុង គីង ស៊ីង** (Dato'Sri Tiong King Sing) រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សិល្បៈ និង វប្បធម៌ ម៉ាឡេស៊ី និង ជាប្រធានគណៈកម្មការអង្គការទេសចរណ៍ពិភពលោក ប្រចាំតំបន់អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក;
- ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍;
- ឯកឧត្តម, លោកជំទាវ, រដ្ឋមន្ត្រី និង ថ្នាក់ដឹកនាំទេសចរណ៍នៃបណ្តាប្រទេសអាស៊ីខាងកើត និង ប៉ាស៊ីហ្វិក និង អាស៊ីខាងត្បូង;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និង អន្តរជាតិ!

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

ថ្ងៃនេះ, ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និង សេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានទទួលនូវការចាត់តាំងពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធ្វើជាអធិបតី ក្នុង **ពិធីបើកកិច្ចប្រជុំរួមលើកទី ៣៥ នៃគណៈកម្មការតំបន់អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក និង គណៈកម្មការតំបន់អាស៊ីខាងត្បូង នៃអង្គការទេសចរណ៍ពិភពលោក** (35th UNWTO CAP & CSA) **និង សន្និសីទអង្គការទេសចរណ៍ពិភពលោក ស្តីពីក្រមអន្តរជាតិសម្រាប់ការការពារទេសចរ** ។ ក្នុងនាម, **សម្តេចតេជោ នាយករដ្ឋមន្ត្រី**, ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមាន ឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់ ដែលបានអញ្ជើញចូលរួមដោយផ្ទាល់ ក្នុងកម្មវិធីដ៏មានអត្ថន័យនេះ ។

កិច្ចប្រជុំរបស់យើងនាឱកាសនេះ អាចរាប់ថា ជាព្រឹត្តិការណ៍ដ៏សំខាន់មួយទៀត របស់កម្ពុជា ក្នុងការទទួលគណៈប្រតិភូអន្តរជាតិជាច្រើនដោយផ្ទាល់, ដែលបានអញ្ជើញមក ពីបណ្តាប្រទេសនានា រហូតដល់ **៣២ ប្រទេស,** បន្ទាប់ពីកម្ពុជាបានទទួលជោគជ័យដ៏ត្រចះ-ត្រចង់ជាប្រវត្តិសាស្រ្ត ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ **កំពូលអាស៊ានលើកទី ៤០ និង ទី ៤១** កាលពីខែ វិច្ឆិកា ឆ្នាំ ២០២២ និង ការទទួលធ្វើជាម្ចាស់ផ្ទះរៀបចំ **កីឡាស៊ីហ្គេម លើកទី ៣២ និង អាស៊ានប៉ារ៉ាហ្គេម លើកទី ១២** ដែលទើបត្រូវបានបិទបញ្ចប់ កាលពីសប្តាហ៍កន្លងទៅ ។

ខ្ញុំសូមយកឱកាសដ៏វិសេសនេះ សម្តែងនូវអំណរគុណចំពោះ **ឯកឧត្តមអគ្គលេខាធិការ** និង ឯកឧត្តម, លោកជំទាវ, ជាសមាជិកទាំងអស់ នៃអង្គការទេសចរណ៍ពិភពលោក ដែលបានគាំទ្រកម្ពុជា ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មការជំនាញទាំងពីរ អមជាមួយសន្និសីទអន្តរជាតិ ក្នុងឆ្នាំ ២០២៣ នេះ ។ ខ្ញុំក៏សូមកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អ រវាងក្រសួងទេសចរណ៍កម្ពុជា និង អង្គការទេសចរណ៍ពិភព-លោក ក្នុងការជំរុញការអភិវឌ្ឍវិស័យទេសចរណ៍សាកលលោក, និយាយជារួម, ក៏ដូចជា វិស័យទេសចរណ៍កម្ពុជា, និយាយដោយឡែក ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

យោងតាមរបាយការណ៍ស្វាគមន៍របស់ **ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍**, ខ្ញុំយល់ថា កិច្ចប្រជុំគណៈកម្មការជំនាញទាំងពីរ អមជាមួយសន្និសីទអន្តរជាតិ

នាពេលនេះ ពិតជាមានភាពចាំបាច់ ក្នុងការប្រមូលធាតុចូលពីភាគីពាក់ព័ន្ធ, ជាពិសេស តំណាងរដ្ឋាភិបាលក្នុងតំបន់ ព្រមទាំងអង្គការជាតិ និង អន្តរជាតិ ក្នុងការដាក់ចេញនូវ ក្រមអន្តរជាតិសម្រាប់ការការពារទេសចរ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និង ភាពជា-ដៃគូរវាងរដ្ឋ និង រដ្ឋ, ពិសេស ការផ្លាស់ប្តូរយោបល់លើមូលបទដ៏មានសារៈសំខាន់ ពោលគឺ **ការការពារទេសចរ ឆ្ពោះទៅការស្តារសេង្គម-សេដ្ឋកិច្ច** តាមរយៈការអភិវឌ្ឍវិស័យទេសចរណ៍ ប្រកបដោយចីរភាព, បរិយាប័ន្ន និង ភាពធន់កាន់តែខ្ពស់ ។

យើងទាំងអស់គ្នាបានជ្រាបស្រាប់ច្បាស់ហើយថា ទេសចរណ៍ គឺជាវិស័យអាទិភាព និង ជាចន្ទល់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និង សង្គម, ពិសេស វិស័យនេះបានជួយលើក-កម្ពស់សេដ្ឋកិច្ចនៅតាមមូលដ្ឋាន និង បានចូលរួមការការពារបរិស្ថាន និង សម្បត្តិវប្បធម៌ ជាតិ ។ ជាក់ស្តែង, កាលពីឆ្នាំ ២០១៩, មុនការមកដល់នៃវិបត្តិជំងឺកូវីដ-១៩, ពិភពលោក បានទទួលភ្ញៀវទេសចរអន្តរជាតិសរុប រហូតដល់ចំនួនប្រមាណ **១ ៥០០ លាននាក់,** ក្នុង អត្រាកំណើន **៤%,** ដោយបានចូលរួមបង្កើតការងារ ចំនួនប្រមាណ **៣៣០ លាននាក់** និង បានបង្កើតចំណូលសម្រាប់សេដ្ឋកិច្ច ចំនួនប្រមាណ **១០,៣%** នៃផលិតផលក្នុងស្រុកសរុប របស់ពិភពលោក ។

យ៉ាងណាមិញ, ដោយសារវិបត្តិជាសកលនៃជំងឺកូវីដ-១៩, ប្រទេសនានាលើសកល លោក, រួមទាំងកម្ពុជាផងដែរ, បានទទួលរងឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរមិនធ្លាប់មាន, ជាពិសេស ខ្សែច្រវាក់ផ្គត់ផ្គង់ទេសចរណ៍ ត្រូវបានកាត់ផ្តាច់ស្ទើរតែទាំងស្រុង ។ អាជីវកម្ម ទេសចរណ៍ជាច្រើន ត្រូវបានផ្អាកដំណើរការ ស្របពេលដែលបុគ្គលិកក្នុងវិស័យទេសចរណ៍ រាប់ម៉ឺននាក់នៅទូទាំងពិភពលោក បានបាត់បង់ការងារ, ជំនាញ និង ទេពកោសល្យរបស់ខ្លួន ហើយប្រទេសនីមួយៗ ក៏ទទួលរងនូវផលអវិជ្ជមានជាច្រើន, ទាំងផ្នែកសង្គម និង សេដ្ឋកិច្ច ។

ទោះជាយ៉ាងណាក្តី, ក្នុងរយៈពេលជិត ៣ ឆ្នាំកន្លងទៅ, យើងពិតជាមានសេចក្តី រីករាយយ៉ាងក្រៃលែង ដែលពិភពលោកទាំងមូលបានខិតខំប្រឹងប្រែង និង រួបរួមគ្នាជាធ្លុង មួយ ដើម្បីឆ្លើយតបទៅនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រោម ស្មារតីនៃការយោគយល់ និង ការចេះជួយគ្នាទៅវិញទៅមក ។ ជាលទ្ធផល, ពិភពលោក បានទទួលជ័យជម្នះលើការប្រយុទ្ធប្រឆាំងនឹងជំងឺដ៏កាចសាហាវនេះ រហូតសម្រេចបាន នូវការបើកដំណើរការប្រទេស និង ការចាប់ផ្តើមស្តារសង្គម-សេដ្ឋកិច្ចរៀងៗខ្លួនឡើងវិញ ។

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

សម្រាប់កម្ពុជា, ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និង ភាពឈ្លាសវៃ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, រាជរដ្ឋាភិបាលបានយកជ័យជម្នះលើការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និង សម្រេចបាននូវ **ភាពស៊ាំសហគមន៍ពេញលេញ និង រឹងមាំ** ដែលជួយធានានូវសុវត្ថិភាព និង សុខភាពសាធារណៈសម្រាប់ប្រជាជនកម្ពុជា ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលកម្ពុជាក៏មានលទ្ធភាពគ្រប់គ្រាន់ ក្នុងការកាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម-សេដ្ឋកិច្ច ឱ្យស្ថិតក្នុងកម្រិតអប្បបរមា តាមរយៈការដាក់ចេញនូវវិធានការអន្តរាគមន៍ជាបន្តបន្ទាប់, បានទាន់ពេល និង ចំទិសដៅ, ប្រកបដោយភាពម្ចាស់ការ និង ការទទួលខុសត្រូវខ្ពស់ ព្រមទាំងបានលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន តាមរយៈការដាក់ចេញនូវវិធានការកែទម្រង់មុតស្រួច និង គោលនយោបាយសំខាន់ៗ សំដៅកែលម្អបរិយាកាសសម្រាប់ធុរកិច្ច និង ការវិនិយោគ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចឱ្យស្ទុះងើបឡើងវិញ ។

សមិទ្ធផលដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងទាំងនេះ បង្កើតបានជាមូលដ្ឋានដ៏រឹងមាំ សម្រាប់ការស្តារ និង ជំរុញសកម្មភាពសង្គម-សេដ្ឋកិច្ច ឱ្យវិលត្រលប់ទៅរកប្រក្រតីភាពឡើងវិញបានយ៉ាងរហ័ស ។ តាមការគណនា និង ព្យាករណ៍ចុងក្រោយ, សេដ្ឋកិច្ចកម្ពុជា, បន្ទាប់ពីបានធ្លាក់ចុះក្នុងអត្រា -៣,១% នៅឆ្នាំ ២០២០, បានស្ទុះងើបឡើងវិញ ក្នុងអត្រា ៣% នៅឆ្នាំ ២០២១, ហើយក្នុងឆ្នាំ ២០២២ សម្រេចបានកំណើន ក្នុងរង្វង់ ៥,២%, ខណៈដែលឆ្នាំ ២០២៣ កំណើនអាចនឹងមាន ក្នុងរង្វង់ ៥,៦% ។ ក្នុងបរិការណ៍នេះ, រាជរដ្ឋាភិបាលនៅតែមានសុទិដ្ឋិនិយម ក្នុងការសម្រេចបាននូវចក្ខុវិស័យ នៃការប្រែក្លាយកម្ពុជា **ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០** និង **ជាប្រទេសមានចំណូលខ្ពស់ នៅឆ្នាំ ២០៥០** ។

សម្រាប់វិស័យទេសចរណ៍កម្ពុជា, ដូច **ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍**, បានគូសបញ្ជាក់ក្នុងសុន្ទរកថាស្វាគមន៍ពីខាងដើម, កម្ពុជាមានសុទិដ្ឋិនិយមថា ចំនួនភ្ញៀវអន្តរជាតិចូលមកកម្ពុជា អាចនឹងត្រលប់ទៅរកស្ថានភាពដូចមុនវិបត្តិជំងឺកូវីដ-១៩, ពោលគឺអាចមានចំនួនប្រមាណ **៧ លាននាក់ នៅឆ្នាំ ២០២៥ ឬ ឆ្នាំ ២០២៦** ខណៈដែលចំនួនភ្ញៀវទេសចរក្នុងស្រុកបានងើបឡើងឆាប់ ដោយអ្នកធ្វើដំណើរកម្សាន្តនៅផ្ទៃក្នុងប្រទេស មានចំនួនប្រមាណ **១៣ លាននាក់** កាលពីឆ្នាំ ២០២២ កន្លងទៅ ដែលចំនួននេះប្រហាក់ប្រហែលនឹងតួលេខ ក្នុងឆ្នាំ ២០១៩, មុនការមកដល់នៃជំងឺកូវីដ-១៩ ។

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ទោះបីវិបត្តិជាសកលនៃជំងឺកូវីដ-១៩ បានស្រាកស្រាន្តគួរឱ្យកត់សម្គាល់ក្តី, ក៏ស្ថាន-ភាព និង ទស្សនវិស័យសេដ្ឋកិច្ចសកល នៅតែបន្តមានភាពផុយស្រួយ និង ងាយប្រឈមនឹងវិបត្តិថ្មី កាន់តែស្មុគស្មាញ ដែលកំពុងកើតឡើងជាបន្តបន្ទាប់, ទាំងក្នុងទិដ្ឋភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន និង ភូមិសាស្ត្រនយោបាយ ។ ការណ៍នេះនឹងបន្តជះឥទ្ធិពលអវិជ្ជមានលើវិស័យទេសចរណ៍សាកលលោក ក៏ដូចជាវិស័យទេសចរណ៍កម្ពុជាផងដែរ ។

ត្រង់ចំណុចនេះ, ខ្ញុំសូមគូសរំលេចបន្ថែមថា លើសពីអត្ថប្រយោជន៍សង្គម-សេដ្ឋកិច្ច, វិស័យទេសចរណ៍ គឺជាភ្នាក់ងារនៃសន្តិភាព និង សុខដុមនីយកម្ម នៃប្រជាជាតិ ពីព្រោះ ការធ្វើដំណើររបស់ភ្ញៀវទេសចរពិភពលោក នាំមកនូវក្តីស្រលាញ់, ការគោរពគ្នាទៅវិញទៅមក និង ការទទួលយកកាន់តែប្រសើរ នូវភាពខុសគ្នាខាងផ្នែកវប្បធម៌ ។ កម្ពុជាតែងស្វាគមន៍ភ្ញៀវទេសចរពីគ្រប់បណ្តាប្រទេសទូទាំងពិភពលោក ដោយមិនមានការរើសអើងឡើយ ។ ជាក់ស្តែង, **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយក-រដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអនុញ្ញាតឱ្យ **នាវាទេសចរណ៍** MS WESTERDAM ចូលចតនៅក្រុងព្រះសីហនុ កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២០ ដើម្បីជួយសង្គ្រោះអាយុជីវិតទេសចរអន្តរជាតិប្រមាណ ២០០ នាក់ ។ ក្នុងន័យនេះ, ក្នុងនាម **សម្តេចតេជោ នាយករដ្ឋមន្ត្រី**, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ **ឯកឧត្តម ហ្សូរាប ប៉ូលូលីកាសវីលី** (Zurab Pololikashvili) **អគ្គលេខាធិការអង្គការទេសចរណ៍ពិភពលោក** ដែលបានធ្វើលិខិតគាំទ្រ និង កោតសរសើរកម្ពុជា ចំពោះករណីនាវាទេសចរណ៍ MS WESTERDAM ដែលធ្វើឱ្យបណ្តាប្រទេសជុំវិញពិភពលោក កាន់តែស្គាល់ និង ចាត់ទុកកម្ពុជាជា «**ប្រទេសតូច ប៉ុន្តែមានចិត្តទូលាយ**» ។

ក្នុងស្មារតីបន្តពង្រឹងការការពារទេសចរ, ការស្តារ និង ការអភិវឌ្ឍទេសចរណ៍ ក្នុងកម្រិតតំបន់ និង ពិភពលោក ឱ្យកាន់តែប្រសើរឡើង ក៏ដូចជាគាំទ្រ និង លើកទឹកចិត្តដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ទេសចរណ៍តំបន់ ឆ្ពោះទៅអនាគត និង វិបុលភាពរួម ឈរលើទស្សនវិស័យ «**គិតពីទេសចរ, គិតពីសេដ្ឋកិច្ច, គិតពីអនាគត**», ខ្ញុំសូមចែករំលែកនូវអនុសាសន៍គន្លឹះមួយចំនួន ដូចខាងក្រោម៖

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

**ទី១.** **សន្តិភាព** គឺពិតជាមិនអាចខ្វះបាន សម្រាប់ទ្រទ្រង់ការអភិវឌ្ឍប្រទេសជាតិ ខណៈដែលក្តីសង្ឃឹមសម្រាប់អនាគត បាន និង កំពុងបង្កើតជាកាលានុវត្តភាព ផ្តើមចេញពីសន្តិភាពនេះ ។ «**គ្មានសន្តិភាព, គ្មានការអភិវឌ្ឍ**»; «**គ្មានសន្តិភាព, គ្មានក្តីសង្ឃឹម**»; «**គ្មានសន្តិភាព, គ្មានការគោរពសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ**»; «**គ្មានសន្តិភាព, គ្មានអ្វីៗទាំងអស់**» ។ កម្ពុជា, ក្នុងនាមជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ និង សន្និសីទអន្តរជាតិនេះ, នឹងចែករំលែកនូវបទពិសោធន៍ និង ការអនុវត្តល្អៗរបស់ខ្លួន ជាមួយសមាជិកអង្គការទេសចរណ៍ពិភពលោក, ក្នុងក្របខណ្ឌតំបន់ទាំងពីរ, ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍របស់ខ្លួន ដែលផ្តើមចេញពីសន្តិភាពដែលខ្លួនរកបានដោយលំបាកបំផុត ជាមួយនឹងក្តីសង្ឃឹម ប្រកបដោយភាពសុទិដ្ឋិនិយម ទៅអនាគត ។

**ទី២.** ខ្ញុំសូមគាំទ្រគំនិតផ្តួចផ្តើមរបស់អង្គការទេសចរណ៍ពិភពលោក ក្នុងការរៀបចំ និង អនុវត្តក្រមអន្តរជាតិ ស្តីពីការការពារទេសចរ (International Code for Protection of Tourists) ដែលរាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតជូន **ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីទេសចរណ៍កម្ពុជា** ចុះហត្ថលេខាទទួលស្គាល់ និង គាំទ្រក្រមអន្តរជាតិនេះ, ក្នុងនាមជាប្រទេសទី ១, ដើម្បីបង្កើនទំនុកចិត្តពីសំណាក់ភ្ញៀវទេសចរ និង ជំរុញការធ្វើដំណើររបស់ទេសចរនៅទូទាំងពិភពលោក ។

**ទី៣.** ខ្ញុំសូមប្រទេសសមាជិកអាស៊ីខាងកើត និង ប៉ាស៊ីហ្វិក និង អាស៊ីខាងត្បូង, អង្គការទេសចរណ៍ពិភពលោក និង អង្គការអន្តរជាតិនានា បន្តពង្រឹងការអភិវឌ្ឍមូលធនមនុស្ស, ខិតខំអនុវត្តក្របខណ្ឌកិច្ចសហប្រតិបត្តិការ ដែលមានស្រាប់ ព្រមទាំងបង្កើនការចែករំលែកបទពិសោធន៍ល្អៗ ជុំវិញការទាក់ទាញ និង ការអភិវឌ្ឍទេពកោសល្យ ដោយគិតគូរផងដែរ នូវការជំរុញកម្មវិធីអក្ខរកម្មឌីជីថល, ការជំរុញសហគ្រិនវ័យក្មេង និង ការជួយគាំទ្រសិប្បកម្ម និង សហគ្រាសធុនមីក្រូ, តូច និង មធ្យម (MSME) ក្នុងវិស័យទេសចរណ៍ ដល់កម្រិតមូលដ្ឋាន និង ត្រូវទាញអត្ថប្រយោជន៍ពីនវានុវត្តន៍, ការតភ្ជាប់ឌីជីថល និង បដិវត្តន៍ឧស្សាហកម្ម ៤.០ ដើម្បីអភិវឌ្ឍទេសចរណ៍តំបន់ ប្រកបដោយភាពវៃឆ្លាត, ចីរភាព និង បរិយាប័ន្ន ព្រមទាំងមានសមត្ថភាពឆ្លើយតបនឹងបញ្ហានៃការប្រែប្រួលអាកាសធាតុ

ប្រកបដោយភាពធន់ ក្រោយវិបត្តិនៃជំងឺកូវីដ-១៩ និង ជំងឺឆ្លងកាចសាហាវផ្សេងទៀត ។

**ទី៤.** យើងត្រូវរួមគ្នាជំរុញការងើបឡើងវិញ នៃវិស័យទេសចរណ៍ ប្រកបដោយភាព-ធន់ ឆ្ពោះទៅអនាគតកាន់តែប្រសើរជាងមុន ប្រកបដោយចីរភាព, គុណភាព និង បរិយាប័ន្ន ។ ក្នុងន័យនេះ, ខ្ញុំសូមអំពាវនាវឱ្យប្រទេសសមាជិក បន្តពង្រឹង និង ពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយដៃគូសន្ទនា និង ដៃគូអភិវឌ្ឍនានា និង កសាងភាពជាដៃគូរវាងរដ្ឋ និង ឯកជន (PPP), ទាំងក្នុងក្របខណ្ឌតំបន់ និង សកលលោក, ឆ្ពោះទៅរកការរីកចម្រើននៃវិស័យទេសចរណ៍ ប្រកបដោយភាពធន់ខ្ពស់ តាមគន្លងប្រក្រតីភាពថ្មី ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ជាថ្មីម្តងទៀត, ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា តាមរយៈកិច្ចពិភាក្សានៅក្នុងសន្និសីទអន្តរ-ជាតិ និង កិច្ចប្រជុំគណៈកម្មការជំនាញទាំងពីរ, យើងនឹងអាចទាញយកនូវទស្សនទានល្អៗ និង ថ្មីៗ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំយុទ្ធសាស្ត្រ, ផែនការ និង បទដ្ឋានគតិយុត្តចាំបាច់នានា ដើម្បីជំរុញកំណើនទេសចរណ៍ពិភពលោកបន្ថែមទៀត ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរឱ្យវេទិកានេះ ប្រព្រឹត្តទៅដោយរលូន ប្រកបដោយផ្លែផ្កា និង ជោគជ័យ តាមការរំពឹងទុក និង សូមឱ្យការស្នាក់នៅរបស់គណៈប្រតិភូទាំងអស់ នៅកម្ពុជា, «**ព្រះរាជាណាចក្រអច្ឆរិយៈ**», ទទួលបាននូវសុខសុវត្ថិភាព, ផាសុកភាព, សេចក្តី-រីករាយ និង ការចងចាំដ៏មានអត្ថន័យ ។ ខ្ញុំក៏សូមជូនពរឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់, ប្រកបដោយពុទ្ធពរ និង ពរ ទាំង ៥ ប្រការ គឺ អាយុ, វណ្ណៈ, សុខៈ, ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជា-**ណាចក្រកម្ពុជា**, ខ្ញុំសូមប្រកាសបើក **កិច្ចប្រជុំរួមលើកទី ៣៥ នៃគណៈកម្មការចម្រុះតំបន់អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក និង កិច្ចប្រជុំគណៈកម្មការចម្រុះតំបន់អាស៊ីខាងត្បូង នៃអង្គការទេសចរណ៍ពិភពលោក និង សន្និសីទអង្គការទេសចរណ៍ពិភពលោក ស្តីពីក្រមអន្តរជាតិសម្រាប់ការការពារទេសចរ** ចាប់ពីពេលនេះតទៅ ៕

***សូមអរគុណ!***